# ភាពសមហេតុផលសម្រេចអនុញ្ញាតឱ្យកសិណសាក្សីដ៏ជំនាញបន្តនៅទៀត នៅក្នុងអង្គជំនុំជម្រះសេចក្តីប្រឆាំងនឹង ឌុច

*ដោយ ឡូរ៉ា ម៉ាកដូណូល៍*

*ថ្ងៃទី ២១ ខសភា ឆ្នាំ២០០៩*

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

## ដំណោះស្រាយដ៏សមហេតុផលលើជម្លោះនីតិវិធី

អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា ខ្លួននឹងរៀបចំដំណើរការនីតិវិធីដោយសម្ងាត់ដើម្បីដោះស្រាយជម្លោះនីតិវិធីដ៏ក្តៅគគុកដែលបានបញ្ចប់កាលពីម្សិលមិញនេះ ជាពិសេសលើបញ្ហាមួយថា តើ អាឡិច សាន់ឌឺ បេិត សហព្រះរាជអាជ្ញាអន្តរជាតិ គួរតែអានសេចក្តីសង្ខេបនៃឯកសារចំនួន១៤៨ ដែលដកស្រង់ចេញពីសក្ខីកម្មដ៏ជំនាញរបស់ ក្រេក អេតឆេសាន់ ឬយ៉ាងណា ដើម្បីឲ្យឯកសារទាំងនោះក្លាយជាភស្តុតាង«ដាក់នៅចំពោះមុខអង្គជំនុំជម្រះ» ដោយយោងទៅតាមខ្លឹមសារនៃវិធានផ្ទៃក្នុងទី៨៧ ។ គួរឲ្យកត់សម្គាល់ ភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងកិច្ចដំណើការនីតិវិធីដោយសម្ងាត់នេះទេ ប៉ុន្តែផ្ទុយទៅវិញ ជនត្រូវចោទ កាំង ហ្កេកអ៊ាវ (ហៅ ឌុច) បែរជាត្រូវបានអនុញ្ញាតឲ្យចូលរួម ។

ប៉ុន្មានម៉ោងក្រោយមក ចៅក្រមបានវិលត្រឡប់មកវិញ ដោយចេញសេចក្តីសម្រេចដ៏សមហេតុផលមួយ ។ ក្រោយពីបានអះអាងកាលពីម្សិលមិញថា ក្រេក អេតឆេសាន់ គឺជាអ្នកនាំពាក្យឲ្យព្រះរាជអាជ្ញា ក្នុងអំឡុងពេលដំណើរការនីតិវិធីដោយសម្ងាត់ មេធាវីការពារក្តីបានទទួលស្គាល់ពីជំនាញរបស់ ក្រេក អេតឆេសាន់ និងទទួលយករបាយការណ៍ដ៏ជំនាញនោះ ។ មេធាវីការពារក្តីបានបន្តទទួលស្គាល់បន្ថែមទៀតថា របាយការណ៍ដ៏ជំនាញ និងឯកសារឧបសម្ព័ន្ធរបស់របាយការណ៍នេះ ត្រូវបានក្លាយជាភស្តុតាង«ដាក់នៅចំពោះមុខអង្គជំនុំជម្រះ» យោងទៅតាមសិទ្ធិរបស់មេធាវីការពារក្តីក្នុងការជំទាស់រាល់ឯកសារទាំងអស់ ឬផ្នែកខ្លះនៃឯកសារនោះ ។ ចៅក្រមបានចាត់ទុកឯកសារឧបសម្ព័ន្ធ និងឯកសារទាំងអស់ដែលបានលើកឡើងកន្លងមក ថាជាផ្នែកដ៏សំខាន់នៃរបាយការណ៍នេះ ។ ដោយមានលក្ខណៈសមហេតុផល សេចក្តីសម្រេចនេះបានសន្សំនូវពេលវេលាបានយ៉ាងច្រើនម៉ោងប្រសិនបើចៅក្រមសម្រេច

មិនឲ្យមានការអានសេចក្តីសង្ខេបនៃឯកសារទាំងនោះ ។ ចៅក្រមមិនបានប្រកាសពីសេចក្តីសម្រេចលើនីតិវិធីទូទៅនោះទេ ប៉ុន្តែបែរជាធ្វើការយោងទៅតាមរបាយការណ៍ដ៏ជំនាញនេះ និងឯកសារឧបសម្ព័ន្ធរបស់របាយការណ៍នោះទៅវិញ ។

ដោយនិយាយទៅកាន់អ្នកតាមដានដំណើរការរបស់តុលាការ ពីការចរចារជាសម្ងាត់មួយភ្លែតនោះ ហ្វ្រង់ស្វ័រ រូ មេធាវីការពារក្តីអន្តរជាតិ បានលើកឡើងពីភាពខុសប្លែកគ្នារវាងរយៈពេលមុនខែកក្កដា ឆ្នាំ២០០៧ ជាពេលដែលរបាយការណ៍ជំនាញរបស់ ក្រេក អេតឆេសាន់ បានប្រគល់ជូនអង្គជំនុំជម្រះ និងរយៈពេលក្រោយខែកក្កដា ឆ្នាំ២០០៧ ។ មុនខែកក្កដា ឆ្នាំ២០០៧ ហ្វ្រង់ស្វ័រ រូ បានអះអាងថា ក្នុងអំឡុងពេលនោះបើទោះបីជា ក្រេក អេត ឆេសាន់ មានទំនាក់ទំនងជាមួយនឹងព្រះរាជអាជ្ញាក៏ដោយ ក៏ ឌុច មិនទាន់ទទួលរងការចោទប្រកាន់ពីតុលាការនៅឡើយដែរ ។ ដូច្នេះឯកសារដ៏ជំនាញនេះពិតជាមានលក្ខណៈត្រឹមត្រូវឥតលំអៀង ។ ហ្វ្រង់ស្វ័រ រូ បានទទូចសុំឲ្យលោកបណ្ឌិតកុំធ្វើកសិណសាក្សី ដោយយោងទៅតាមផ្នែកខ្លះដែលមាននៅក្នុងសំណុំរឿងក្នុងអំឡុងពេលបន្ទាប់ពីខែកក្កដា ឆ្នាំ២០០៧ ក្រោយពីការប្រគល់ជូនរបាយការណ៍ដ៏ជំនាញរបស់លោកដល់អង្គជំនុំជម្រះនោះឡើយ ។ បន្ទាប់ពីមានការរាំងស្ទះផ្នែកនីតិវិធីអស់រយៈពេលពីរថ្ងៃកន្លងមកនេះ សហព្រះរាជអាជ្ញាក៏អាចធ្វើការចោទសួរទៅកាន់ ក្រេក អេតឆេសាន់ ។

## កសិណសាក្សីដ៏ជំនាញរបស់ ក្រេក អេតឆេសាន់

ដោយធ្វើការឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា ក្រេក អេតឆេសាន់ បានពន្យល់ថា “អំណាចរំលោភបំពានយ៉ាងខ្លាំងក្លា” ត្រូវបានបង្កាប់បង្រៀននៅក្នុងរបបខ្មែរក្រហម ។ តាមមាត្រា១០ នៃច្បាប់ធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ សកម្មភាពដ៏គ្រោះថ្នាក់ជាច្រើនដែលធ្វើឡើងដើម្បីប្រឆាំងនឹងរដ្ឋត្រូវបានផ្តន្ទាទោសដល់កម្រិតដ៏ធ្ងន់ធ្ងរបំផុត ។ ដោយសារតែ “ការប្រឆាំងនឹងរដ្ឋ” ត្រូវបានផ្សព្វផ្សាយយ៉ាងទូលាយ និងដោយសារគ្មានប្រព័ន្ធច្បាប់ ការកាត់ទោសប្រហារជីវិតត្រូវបានអនុវត្តលើប្រភេទបទឧក្រិដ្ឋមួយចំនួនធំ ។

ក្រេក អេតឆេសាន់ បានចាត់ទុកការកាត់ទោសក្នុងបក្សកុម្មុយនីស្តកម្ពុជា គឺជាគោលការណ៍សំខាន់របស់ “ការគ្រប់គ្រងជាឯករាជ្យ” ។ លោកបណ្ឌិតបានពន្យល់ប្រាប់ថា បក្សកុម្មុយនីស្តកម្ពុជាបានចាត់

ទុកបដិវត្តន៍កុម្មុយនីស្តរបស់ខ្លួនថាមានលក្ខណៈខុសប្លែកតែមួយគត់ ដូច្នេះបក្សកុម្មុយនីស្តកម្ពុជាមិនចាំបាច់ស្វែងរកការណែនាំពីរបបបដិវត្តន៍ដទៃពីមុនទៀតឡើយ ។ លើសពីនេះទៅទៀត បក្សកុម្មុយនីស្តកម្ពុជាជឿថា របបបដិវត្តន៍ផ្សេងទៀតទទួលបរាជ័យដោយសារតែពួកវណ្ណៈកេងប្រវ័ញ្ចមិនទាន់ត្រូវបានកម្ចាត់ចោលគ្រប់គ្រាន់នៅឡើយ ដូច្នេះ បក្សកុម្មុយនីស្តកម្ពុជាមានគោលបំណងលុបបំបាត់ពួកវណ្ណៈកេងប្រវ័ញ្ចទាំងនោះទាំងស្រុង មានន័យថាមនុស្សដែលនៅក្នុងវណ្ណៈនេះនឹងត្រូវបានសម្លាប់ ឬត្រូវប្រែក្លាយជាកសិករ ។

ក្រេក អេតឆេសាន់ បានរៀបរាប់ពីគោលការណ៍សំខាន់ដទៃផ្សេងទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា ៈ ភាពបរិសុទ្ធ ។ តាមលក្ខន្តិកៈ សមាជិកបក្សកុម្មុយនីស្តកម្ពុជាត្រូវបានកំណត់ឲ្យមានសីលធម៌ និងគោលនយោបាយ “ត្រឹមត្រូវ និងស្អាតស្អំ” ។ ភស្តុតាងបានបង្ហាញថា ឌុច បានធ្វើដំណើរទៅកាន់ស្រុកក្រីក្រដើម្បីរើសយុវជនក្មេងៗមកធ្វើជាបុគ្គលិករបស់មន្ទីរស-២១ ដែលត្រូវបានស្គាល់ថាគុកទួលស្លែង ដោយសារតែយុវជនទាំងនេះគឺជា “បេក្ខជនដែលមានភាពស្អាតស្អំ” ដែលមិនទទួលឥទ្ធិពលពីប្រភពផ្សេងៗ ។

ជាមួយគ្នានេះ លោកក៏បានផ្តល់ជាព័ត៌មានលម្អិតពីទំនាក់ទំនងនៅក្នុងឋានានុក្រមរបស់បក្សកុម្មុយនីស្តកម្ពុជា ។ កម្មាភិបាលថ្នាក់ទាបបានសិក្សាស្វែងយល់ពី“មាគ៌ា” ឬគោលនយោបាយបក្សពីប្រភពជាច្រើនរួមមាន ការប្រជុំសាលាបណ្តុះបណ្តាលរបស់បក្ស អត្ថបទសារព័ត៌មានរបស់បក្ស និងជំរុំកសាងខ្លួន ។ ទំនាក់ទំនងត្រូវមានភាពទៀងត្រង់យ៉ាងហ្មត់ចត់ជាទីបំផុត ។ ឧទាហរណ៍ ជាលទ្ធផលស្រុកចំនួនពីរមិនអាចធ្វើការទាក់ទងគ្នាដោយផ្ទាល់នោះទេ ។ ជាងនេះទៅទៀត អង្គភាពទាំងអស់ត្រូវបានបង្ខំឲ្យរាយការណ៍ជាទៀងរាល់សប្តាហ៍ទៅកាន់អង្គភាពជាន់ខ្ពស់ភ្លាមៗ ដើម្បីឲ្យព័ត៌មានទាំងអស់នោះបញ្ជូនទៅឲ្យបច្ចិមបក្សបានដឹងពុ ។ ទំនាក់ទំនងដែលធ្វើឡើងខាងក្រៅបណ្តាញត្រង់ត្រូវបានចាត់ទុកថា ជាអំពើក្បត់ ជាពិសេសគឺនៅក្នុងរបនាសម្ព័ន្ធយោធា ។

នៅថ្ងៃទី២៥ និង ២៦ ខែឧសភា អង្គជំនុំជម្រះនឹងស្តាប់កសិណសាក្សីស្តីពីជម្លោះប្រដាប់អាវុធពីសាក្សីជំនាញម្នាក់ទៀតគឺ ណាយ៉ាន់ ចាន់ដា ។ ក្រេក អេតឆេសាន់ នឹងត្រូវកោះហៅម្តងទៀតនៅពេលក្រោយដើម្បីឲ្យមកបញ្ចប់កសិណសាក្សីរបស់លោក ។